អគ្គលេខាធិការដ្ឋាន (ព្រឹទ្ធសភា)

ចូល

លេខ..........

ថ្ងៃទី........ម៉ោង........

បញ្ជូនទៅ..........

នស/រកម/០១០២/០០៣

# ព្រះរាជក្រម

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល-កម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី៩ របស់អាស៊ានស្តីពីភាតព្វកិច្ចធានារ៉ាប់រងយានយន្ត ដែលរដ្ឋសភាបានអនុម័តកាល ពីថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៧ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភា បានអនុម័តយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២០ ខែ ធ្នូ ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើក ទី ៦ នីតិកាលទី ១ ហើយដែលមាន សេចក្តីទាំងស្រុង ដូចតទៅ :

# ច្បាប់

## ស្តីពី

## ការអនុម័តយល់ព្រមលើពិធីសារទី ៥ របស់អាស៊ាន ស្តីពីកាតព្វកិច្ចធានារ៉ាប់រងយានយន្ត

**មាត្រា ១.-**

អនុម័តយល់ព្រមលើពិធីសារទី ៥ របស់អាស៊ានស្តីពីកាតព្វកិច្ចធានារ៉ាប់រងយានយន្ត ដែលត្រូវបានចុះហត្ថលេខានៅទីក្រុងគូឡាលំពួរ ប្រទេសម៉ាឡេស៊ី នាថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០១ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តពិធីសារនេះ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០៦

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាប់បង្គាប់

ប្រមុខរដ្ឋស្តីទី

ចរល.០៤.០១.០០៧

ហត្ថលេខា

ជា ស៊ីម

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ហត្ថលេខា

គាត ឈន់

លេខ: ០៨ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៦

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

# ពិធីសារ ៥

## របស់អាស៊ានស្តីពីភាគពួកិច្ចធានារ៉ាប់រងយានយន្ត

រដ្ឋាភិបាលនៃប្រទេសប្រ៊ុយណេដារូសាឡាំ ព្រះរាជាណាចក្រកម្ពុជា សាធារណៈរដ្ឋឥណ្ឌូណេស៊ី សាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ប្រទេសម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណៈរដ្ឋហ្វីលីពីន សាធារណៈរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណៈរដ្ឋសង្គមនិយមវៀតណាម រដ្ឋជាសមាជិកនៃសមាគមប្រជាជាតិអាស៊ីអគ្នេយ៍ (តទៅនេះហៅថា "ភាគីនៃកិច្ចសន្យា") ។

ការរំលឹកឡើងវិញ នូវកិច្ចព្រមព្រៀងក្នុងក្របខ័ណ្ឌអាស៊ានស្តីពីការសម្រួលក្នុងការដឹកជញ្ជូនទំនិញឆ្លងកាត់ ដែលបានចុះហត្ថលេខាកាលពីថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៩៨ នៅទីក្រុងហាណូយ ប្រទេសវៀតណាម (តទៅនេះ ហៅថា "កិច្ចព្រមព្រៀង") ។

ការទទួលស្គាល់ថា មាត្រា ១៤ និងមាត្រា ២៥ នៃកិច្ចព្រមព្រៀងនេះ ចែងអំពីការចុះហត្ថលេខាលើពិធីសារអនុវត្តន៍ ដែលជាផ្នែកមួយនៃកិច្ចព្រមព្រៀង ។

ការរំលឹកឡើងវិញផងទៀតថា ផែនការសកម្មភាពនាទីក្រុងហាណូយដែលបានអនុម័តដោយ ប្រមុខរដ្ឋ និង រដ្ឋាភិបាលនៃប្រទេសអាស៊ាននាសម័យប្រជុំកំពូលអាស៊ានលើកទី៦ នៅទីក្រុងហាណូយ ប្រទេសវៀតណាម កាលពីថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ១៩៩៨ ចែងពីការប្រតិបត្តិកិច្ចព្រមព្រៀងនៅឆ្នាំ ២០០០ ។

ដោយស្មារតីនៃ សេចក្តីត្រូវការក្នុងការទូទាត់សំណងដល់ជនរងគ្រោះដោយគ្រោះថ្នាក់ចរាចរផ្លូវគោក បណ្តាលមកពីអ្នកដឹកជញ្ជូនឆ្លងកាត់ និងមធ្យោបាយដឹកជញ្ជូនឆ្លងកាត់ផ្លូវគោក ចំពោះការខូចខាតដែលពួកគេទទួលរង បណ្តាលមកពីគ្រោះថ្នាក់នេះ ។

ហេតុនេះហើយនៅពេលនេះ ភាគីនៃកិច្ចសន្យាបានព្រមព្រៀងគ្នាដូចខាងក្រោម ÷

### មាត្រា១

### និយមន័យ

សំរាប់គោលបំណងនៃពិធីសារនេះ ពាក្យដូចតទៅនេះនឹងមានន័យដូចខាងក្រោម ÷

ក-ការិយាល័យជាតិ ( National Bureau ) មានន័យថាទីភ្នាក់ងារ ដែលបានតែងតាំងត្រឹមត្រូវក្នុងភាគីនៃកិច្ចសន្យានីមួយៗ ដើម្បីបំពេញមុខងារចាំបាច់សំរាប់កិច្ចប្រតិបត្តិការរបស់អាស៊ានស្តីពីកាតព្វកិច្ចធានារ៉ាប់រងយានយន្ត ដូចដែលបានបង្កើតនៅក្នុងពិធីសារនេះ ។

ខ-អ្នកធានារ៉ាប់រង ( Insurer ) មានន័យថាក្រុមហ៊ុនធានារ៉ាប់រង ដែលជាសមាជិករបស់ការិយាល័យជាតិណាមួយនៃបណ្តាការិយាល័យជាតិ។

គ-ក្រុមប្រឹក្សាការិយាល័យ ( Council of Bureau ) មានន័យថាអង្គភាពដែលបានបង្កើតឡើងដោយតំណាងនៃការិយាល័យជាតិទាំងអស់ ដូចដែលបានបង្កើតឡើងតាមមាត្រា ១១ នៃពិធីសារនេះ ។

ឃ-ប័ណ្ណពណ៌ខៀវ ( Blue Card ) មានន័យថា ជាប័ណ្ណសំគាល់អត្តសញ្ញាណកម្មដែលបង្ហាញពីប័ណ្ណសន្យារ៉ាប់រងលើកាតព្វកិច្ចធានារ៉ាប់រងយានយន្ត ដែលចេញដោយការិយាល័យជាតិរបស់ភាគីនៃកិច្ចសន្យា ដោយអនុលោមទៅតាមល័ក្ខខ័ណ្ឌនៃពិធីសារនេះ ។

ង- យានយន្តដឹកជញ្ជូនឆ្លងកាត់ផ្លូវគោក ( Road Transit Transport Vehicle ) មានន័យថាប្រភេទយានយន្តផ្លូវគោកប្រើប្រាស់ដឹកទំនិញឆ្លងកាត់ដែនដីរបស់ភាគីនៃកិច្ចសន្យាមួយឬច្រើន នៅពេលឆ្លងកាត់ដែនដីទាំងនោះ ដោយមានឬគ្មានការផ្ទេរទំនិញ ការបញ្ចូលឃ្លាំង ការបំបែកជាចំណែកនូវទំនិញចាក់ចារ ឬផ្លាស់ប្តូររបៀបដឹកជញ្ជូនគ្រាន់តែជាចំណែកមួយនៃការធ្វើដំណើរទាំងស្រុង ដែលចាប់ផ្តើម ឬបញ្ចប់ក្រៅពីព្រំដែនរបស់ភាគីនៃកិច្ចសន្យាមួយឬច្រើន ដែលយានយន្តធ្វើដំណើរឆ្លងកាត់ ដូចបានពិពណ៌នានៅលើវិញ្ញាបនប័ត្រធានារ៉ាប់រង ឬនៅលើប័ណ្ណពណ៌ខៀវ។

ច-ប័ណ្ណសន្យារ៉ាប់រង ( Insurance policy ) មានន័យថាជាឯកសារចុះកិច្ចសន្យាដែលចេញដោយក្រុមហ៊ុនធានារ៉ាប់រង ឱ្យទៅអ្នកត្រូវបានធានារ៉ាប់រងដើម្បីធានាលើមរណៈភាព ឬរបួសរាងកាយ និង/ឬការខូចខាតទ្រព្យសម្បត្តិបង្កឡើងដោយការប្រើប្រាស់យានយន្តដឹកជញ្ជូនឆ្លងកាត់តាមផ្លូវគោក ។

ឆ-ម្ចាស់ប័ណ្ណសន្យារ៉ាប់រង ( Policy Holder) មានន័យថា នីតិបុគ្គល ឬរូបវន្តបុគ្គលដែលទិញប័ណ្ណសន្យារ៉ាប់រងលើកាតព្វកិច្ចធានារ៉ាប់រងយានយន្ត ឬបុគ្គលណាមួយដែលកាន់បណ្ណ័ពណ៌ខៀវមានសុពលភាព ។

ជ-គ្រោះថ្នាក់ចរាចរ ( Road Traffic Accident ) មានន័យថាព្រឹត្តិការណ៍ ឬហេតុការណ៍ចៃដន្យដែលកើតមានឡើងទាក់ទងទៅនឹងយានយន្តដឹកជញ្ជូនឆ្លងកាត់ផ្លូវគោក បង្កឱ្យមានមរណៈភាព ឬរបួសរាងកាយ និង/ឬការខូចខាតទ្រព្យសម្បត្តិ ។

ឈ-ប្រតិបត្តិករដឹកជញ្ជូនឆ្លងកាត់ មានន័យថាម្ចាស់ អ្នកបើកបរ និង/ឬ ភ្នាក់ងារនៃយានយន្ត ដឹកជញ្ជូនឆ្លងកាត់ផ្លូវគោក ដែល(១) មានការអនុញ្ញាតពីប្រទេសរបស់ខ្លួនត្រឹមត្រូវ ឬមានអាជ្ញាប័ណ្ណ ដើម្បីផ្តល់សេវាដឹកជញ្ជូន ហើយដែលមានឯកសារបញ្ជាក់ពីការគោរពវិធាន និងនិតិវិធីនានា ដែលមាន ចែងនៅក្នុងការអនុញ្ញាត ឬអាជ្ញាប័ណ្ណ និង(២) បានចុះបញ្ជីត្រឹមត្រូវជាប្រតិបត្តិករដឹកជញ្ជូនឆ្លងកាត់ ដោយគណៈកម្មាធិការជាតិសំរបសំរួលផ្នែកដឹកជញ្ជូនឆ្លងកាត់រៀងៗខ្លួន National Transit Transport Coordinating Committee ( NTTCC ) ។

## មាត្រា២

## ការអនុវត្តន៍

អនុលោមទៅតាមមាត្រា ៣ និងវាក្យខ័ណ្ឌ២ និង៣នៃមាត្រា ១៤ នៃកិច្ចព្រមព្រៀងភាគីនៃកិច្ចសន្យា ទាំងនេះ យល់ព្រមអនុវត្តល័ក្ខខ័ណ្ឌទាំងឡាយនៃពិធីសារនេះ អំពីការបង្កើតគំរោងការណ៍អាស៊ានលើកាតព្វកិច្ច ធានារ៉ាប់រងយានយន្ត ដើម្បីអោយប្រតិបត្តិករដឹកជញ្ជូនឆ្លងកាត់ និងយានយន្តដឹកជញ្ជូនឆ្លងកាត់លើផ្លូវគោកពី សំណាក់ភាគីនៃកិច្ចសន្យានីមួយៗ អាចត្រូវបានធានាគ្រប់គ្រាន់លើមរណៈភាព ឬរបួសរាងកាយ និង/ឬការខូច ខាតទ្រព្យសម្បត្តិដែលបង្កឡើងដោយគ្រោះថ្នាក់ចរាចរផ្លូវគោកក្នុងដែនដីរបស់ភាគីនៃកិច្ចសន្យាដទៃទៀត ។

## មាត្រា ៣

## វិសាលភាពនៃកាតព្វកិច្ចធានារ៉ាប់រងយានយន្ត

គំរោងការណ៍អាស៊ានស្តីពីកាតព្វកិច្ចធានារ៉ាប់រងយានយន្ត ដូចដែលបានបង្កើតឡើងក្នុងពិធីសារនេះ និង ផ្តល់យ៉ាងហោចណាស់នូវតំរូវការជាអប្បបរមាដែលចែងក្នុងច្បាប់ និងបទប្បញ្ញត្តិសំរាប់គ្រប់គ្រងកាតព្វកិច្ច ធានារ៉ាប់រងយានយន្ត ដែលស្ថិតនៅជាថេរមានក្នុងប្រទេសមួយ ឬប្រទេសនានាសំរាប់ការឆ្លងកាត់ និងជា គោលដៅចុងបញ្ចប់ ។

## មាត្រា ៤

## កាតព្វកិច្ចរបស់ភាគីនៃកិច្ចសន្យា

ក្រៅពីការទទួលខុសត្រូវនានា ដែលបានកំណត់ក្នុងល័ក្ខខ័ណ្ឌនៃពិធីសារនេះ ភាគីនៃកិច្ចសន្យាត្រូវខិតខំ ចាត់វិធានការចាំបាច់នានាសំរាប់ការអនុវត្តន៍ពិធីសារនេះ និងជាពិសេស ÷

ក-ចាត់ចែងការងារតំរូវឱ្យក្រុមហ៊ុនធានារ៉ាប់រងមួយ ឬច្រើនដែលបានបង្កើតនៅក្នុងដែនដីរបស់ខ្លួន ដោយផ្តល់កាតព្វកិច្ចធានារ៉ាប់រងយានយន្ត ដើម្បីអនុម័តគំរោងការណ៍ប័ណ្ណពណ៌ខៀវ ដូចដែលបានពិពណ៌នាក្នុងពិធីសារនេះ ។

ខ-ចាត់ចែងអោយអនុម័តច្បាប់ និងបទប្បញ្ញត្តិចាំបាច់ក្នុងប្រទេស ដែលអាចតំរូវសំរាប់ការអនុវត្តន៍ពិធីសារនេះ ។

គ-ចាត់ចែងការងារដើម្បីឱ្យមានភាពប្រាកដថា ការិយាល័យជាតិរបស់ខ្លួនមានមូលនិធិគ្រប់គ្រាន់ដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួន ដូចមានចែងនៅក្នុងមាត្រា១០ នៃពិធីសារនេះ ។

## មាត្រា ៥

## កាតព្វកិច្ចតំរូវឱ្យមានប័ណ្ណពណ៌ខៀវ

យានយន្តដឹកជញ្ជូនឆ្លងកាត់ផ្លូវគោកត្រូវមានប័ណ្ណពណ៌ខៀវដែលមានសុពលភាព ដើម្បីបង្ហាញនៅពេលមានការស្នើសុំ ។

## មាត្រា ៦

## ការចេញប័ណ្ណពណ៌ខៀវ

ប័ណ្ណពណ៌ខៀវនឹងត្រូវចេញដោយការិយាល័យជាតិរបស់ភាគីនៃកិច្ចសន្យានីមួយៗ ដោយអនុលោមទៅតាមមាត្រា ១០ នៃពិធីសារនេះ ។

## មាត្រា ៧

## វិសាលភាព និងសុពលភាពនៃប័ណ្ណពណ៌ខៀវ

១-ក្នុងកំឡុងពេលមានសុពលភាព ប័ណ្ណពណ៌ខៀវនឹងប្រើប្រាស់ជាតឹកតាងបង្ហាញនូវអត្ថិភាពនៃប័ណ្ណសន្យារ៉ាប់រងលើកាតព្វកិច្ចធានារ៉ាប់រងយានយន្ត ដែលបានរៀបរាប់ក្នុងមាត្រា ៣ នៃពិធីសារនេះ ។

២-ប័ណ្ណពណ៌ខៀវនឹងត្រូវមានសុពលភាពសំរាប់រយៈពេលជាក់លាក់ និងមិនឱ្យលើសមួយឆ្នាំប្រតិទិនដោយមិនគិតចំនួនជើងដឹកជញ្ជូនឆ្លងកាត់ឡើយ ។

៣-ប័ណ្ណពណ៌ខៀវនឹងមានសុពលភាព សំរាប់យានយន្តដឹកជញ្ជូនឆ្លងកាត់តាមផ្លូវគោគមួយជាក់លាក់ និងមិនអាចផ្ទេរបានឡើយទោះក្នុងករណីណាក៏ដោយ ។

## មាត្រា ៨

## មាតិកា និងទំរង់នៃប័ណ្ណពណ៌ខៀវ

១-ប័ណ្ណពណ៌ខៀវនឹងបញ្ជាក់ពីលក្ខណៈពិសេសដូចខាងក្រោម ÷

ក- ឈ្មោះ និងអាស័យដ្ឋាននៃការិយាល័យជាតិចេញប័ណ្ណ

ខ- ប្រទេសដែលប័ណ្ណសន្យាធានារ៉ាប់រងមានសុពលភាព

គ- ឈ្មោះ និងអាស័យដ្ឋាននៃក្រុមហ៊ុនធានារ៉ាប់រង

ឃ- អត្តសញ្ញាណកម្មរបស់យានយន្ត ដែលដឹកជញ្ជូនឆ្លងកាត់ផ្លូវគោក

ង- ឈ្មោះ និងអាស័យដ្ឋានម្ចាស់ប័ណ្ណសន្យារ៉ាប់រង

ច- កាលបរិច្ឆេទចេញប័ណ្ណ និងផុតសុពលភាព

ឆ- ឈ្មោះ និងអាស័យដ្ឋានរបស់ការិយាល័យជាតិនៅក្នុងភាគីនៃកិច្ចសន្យានីមួយៗ

ជ- លេខប័ណ្ណសន្យារ៉ាប់រង

ឈ- លេខរៀងរបស់ប័ណ្ណ និង

ញ- ហត្ថលេខា និងត្រា របស់ការិយាល័យជាតិចេញប័ណ្ណ

២-ទ្រង់ទ្រាយ ល័ក្ខខ័ណ្ឌនៃទំហំ និង សណ្ឋានរបស់ប័ណ្ណពណ៌ខៀវ ដែលនឹងត្រូវសំរេចដោយក្រុមប្រឹក្សានៃការិយាល័យ ។ ប័ណ្ណនេះត្រូវបោះពុម្ពជាភាសាអង់គ្លេស ។

## មាត្រា ៩

## ការបង្កើតការិយាល័យជាតិ

១- ភាគីនៃកិច្ចសន្យានឹងត្រូវបង្កើតការិយាល័យជាតិ ដែលមានមុខងារដូចបានចែងក្នុងមាត្រា ១០ នៃពិធីសារនេះ ។

២-ការិយាល័យជាតិនឹងត្រូវបានបង្កើតឡើងដោយក្រុមហ៊ុនធានារ៉ាប់រង ដែលមានអាជ្ញាប័ណ្ណក្នុងការផ្តល់កាតព្វកិច្ចធានារ៉ាប់រងយានយន្ត។

## មាត្រា ១០

## មុខងាររបស់ការិយាល័យជាតិ

ការិយាល័យជាតិនឹងទទួលបំពេញនូវមុខងារដូចខាងក្រោម ÷

ក-ចេញប័ណ្ណពណ៌ខៀវឱ្យទៅប្រតិបត្តិករដឹកជញ្ជូនឆ្លងកាត់ក្នុងប្រទេសរបស់ខ្លួន បន្ទាប់ពីបានពិនិត្យឃើញថា ប្រតិបត្តិករនោះមានប័ណ្ណសន្យារ៉ាប់រងយានយន្តដែលឆ្លើយតបទៅនឹងតំរូវការនៃកាតព្វកិច្ចធានារ៉ាប់រងយានយន្តរបស់ប្រទេស ។

ខ-លក់ប័ណ្ណសន្យារ៉ាប់រងយានយន្តរបស់ប្រទេស ដែលផ្តល់កាតព្វកិច្ចធានារ៉ាប់រងសិតអប្បបរមាដល់ប្រតិបត្តិករដឹកជញ្ជូនឆ្លងកាត់ប្រទេសដទៃទៀត ដែលចូលទៅក្នុងប្រទេសនោះ ។

គ-បោះត្រានៅលើប័ណ្ណពណ៌ខៀវក្រោយពីការផ្ទៀងផ្ទាត់ឃើញថា ប្រតិបត្តិករដឹកជញ្ជូនឆ្លងកាត់ប្រទេសដទៃទៀតបានទិញប័ណ្ណសន្យារ៉ាប់រងយានយន្តដែលតំរូវឱ្យមាន ដោយឆ្លើយតបទៅនឹងការទាមទារផ្នែកកាតព្វកិច្ចធានារ៉ាប់រងយានយន្តរបស់ប្រទេស ។

ឃ-នៅពេលមានការផ្តល់ពត៌មានអំពីគ្រោះថ្នាក់ចរាចរផ្លូវគោក ដែលបង្កឡើងក្នុងដែនដីរបស់ខ្លួនដោយម្ចាស់ប័ណ្ណពណ៌ខៀវនោះ ត្រូវផ្ទៀងផ្ទាត់ស្ថានភាពនៃគ្រោះថ្នាក់ និងផ្នែកលើការស៊ើបអង្កេតរបស់ខ្លួន ចាត់វាលវិធានការដែលចាំបាច់ ។ ក្នុងហេតុការណ៍នេះ ការិយាល័យជាតិត្រូវផ្តល់ពត៌មានដល់ក្រុមហ៊ុនធានារ៉ាប់រង ពាក់ព័ន្ធក្នុងការដោះស្រាយសំណងជំនួសមុខឱ្យក្រុមហ៊ុនធានារ៉ាប់រងនេះ ។

ង-ទទួលការអនុញ្ញាតជាមុនពីក្រុមហ៊ុនធានារ៉ាប់រងពាក់ព័ន្ធ មុននឹងដោះស្រាយសំណងណាមួយ ។

ច-ទាក់ទងក្រុមហ៊ុនធានារ៉ាប់រងដែលពាក់ព័ន្ធ ដើម្បីទាមទារមកវិញនូវទឹកប្រាក់ដែលបានធ្វើសំណងរួចហើយ ។

## មាត្រា ១១

## ការបង្កើតក្រុមប្រឹក្សាការិយាល័យ

ក្រុមប្រឹក្សាការិយាល័យនឹងត្រូវបង្កើតឡើងដើម្បីសំរបសំរួល និង ត្រួតពិនិត្យប្រតិបត្តិការ លើផ្នែកហិរញ្ញវត្ថុ រដ្ឋបាល បច្ចេកទេស និងផ្នែកផ្លូវច្បាប់នៃការិយាល័យជាតិនានា របស់ប្រទេសនៃកិច្ចសន្យា ។

## មាត្រា ១៤

## កិច្ចសំរុះសំរួលស្ថាប័ន

១-កិច្ចប្រជុំនិយតករបានារ៉ាប់រងរបស់អាស៊ាន នឹងទទួលខុសត្រូវចំពោះការពិនិត្យឡើងវិញ នូវការសំរបសំរួល និងការត្រួតពិនិត្យគ្រប់ទិដ្ឋភាពដែលទាក់ទងទៅនឹងការអនុវត្តន៍ពិធីសារនេះឱ្យមានប្រសិទ្ធភាព ។

២-លេខាធិការដ្ឋានអាស៊ាន ត្រូវដាក់ជូននូវរបាយការណ៍ទៀងទាត់ស្តីពីការរីកចំរើននៃការអនុវត្តន៍ពិធីសារនេះ ឱ្យទៅគណៈសំរបសំរួលការដឹកជញ្ជូនឆ្លងកាត់ ដែលបានបង្កើតឡើងអនុលោមទៅតាមមាត្រា ២៩ -២ នៃកិច្ចព្រមព្រៀង ។

៣-លេខាធិការដ្ឋានអាស៊ានត្រូវផ្តល់ការជួយឧបត្ថម្ភ គាំទ្រចាំបាច់ផ្នែកបច្ចេកទេសចំពោះកិច្ចប្រជុំនិយតករបានារ៉ាប់រងអាស៊ាននិងស្ថាប័នអាស៊ាននានា ដែលពាក់ព័ន្ធក្នុងតួនាទី និងការទទួលខុសត្រូវរបស់គេចំពោះពិធីសារនេះ ។

## មាត្រា ១៥

## អវសានប្បញ្ញត្តិ

១-ពិធីសារនេះនឹងតំកល់ទុកដោយអគ្គលេខាធិការអាស៊ាន ដែលនឹងផ្តល់យ៉ាងឆាប់រហ័សនូវច្បាប់ថតចំលង ដែលមានការបញ្ជាក់ទៅឱ្យភាគីនៃកិច្ចសន្យានីមួយៗ ។

២-ពិធីសារនេះនឹងបង្កើតជាចំណែកទាំងមូលនៃកិច្ចព្រមព្រៀង ។

៣-ពិធីសារនេះ ត្រូវស្ថិតនៅក្រោមសច្ចានុមតិ ឬការយល់ព្រមដោយភាគីនៃកិច្ចសន្យា ។ ឯកសារនៃសច្ចានុមតិ ឬការយល់ព្រមនឹងតំកល់ទុកដោយអគ្គលេខាធិការអាស៊ាន ដែលនឹងត្រូវជូនដំណឹងភ្លាមៗដល់ភាគីនៃកិច្ចសន្យានីមួយៗពីការតំកល់នោះ ។

៤-ពិធីសារនេះនឹងចូលជាធរមាន នៅពេលដែលឯកសារនៃសច្ចានុមតិឬការយល់ព្រមដោយភាគីនៃកិច្ចសន្យា ត្រូវបានតំកល់ទុកនៅអគ្គលេខាធិការអាស៊ាន។ ភាគីនៃកិច្ចសន្យាដែលមិនអាចគោរពបានតាមពិធីសារនេះ នឹងត្រូវបានផ្តល់រយៈពេលអនុគ្រោះចំនួន២ឆ្នាំគិតចាប់ពីថ្ងៃចុះហត្ថលេខាលើពិធីសារនេះ ដើម្បីបំពេញ ការងារឆ្ពោះទៅរកការអនុវត្តន៍ឱ្យបាន ។

៥-វិសោធនកម្មណាមួយចំពោះប្រការនានា និងឧបសម្ពន្ធនៃពិធីសារនេះនឹងត្រូវបានអនុវត្តដោយការយល់ព្រមរបស់ភាគីនៃកិច្ចសន្យាទាំងអស់ ។

ដើម្បីជាសក្ខីភាព ហត្ថលេខីដូចខាងក្រោមដែលត្រូវបានអនុញ្ញាតត្រឹមត្រូវដោយរដ្ឋាភិបាលរៀងៗខ្លួន ឱ្យចុះហត្ថលេខាលើពិធីសារ ៥ ស្តីពីគំរោងការណ៍អាស៊ានលើកាតព្វកិច្ចធានារ៉ាប់រងយានយន្ត។

## មាត្រា ១២

## សមាសភាព និងការប្រជុំរបស់ក្រុមប្រឹក្សាការិយាល័យ

១-ក្រុមប្រឹក្សាការិយាល័យ នឹងមានតំណាងម្នាក់មកពីការិយាល័យជាតិនីមួយៗ និងតំណាងម្នាក់របស់គណៈសំរបសំរួលផ្នែកដឹកជញ្ជូនឆ្លងកាត់ដែលបានបង្កើតឡើង អនុលោមទៅតាមមាត្រាទី ២៩-២ នៃកិច្ចព្រមព្រៀង ។

២-ក្រុមប្រឹក្សាការិយាល័យត្រូវបោះឆ្នោតជ្រើសតាំងប្រធាន និងអនុប្រធាន ពីចំណោមសមាជិករបស់ខ្លួនសំរាប់រយៈពេលកំណត់ និងអនុលោមទៅតាមគោលការណ៍ប្តូរវេនគ្នា។

៣-ក្រុមប្រឹក្សាការិយាល័យត្រូវជួបប្រជុំមួយឆ្នាំម្តង ។ ការប្រជុំបន្ថែមអាចនឹងប្រព្រឹត្តទៅតាមការស្នើសុំពីការិយាល័យជាតិណាមួយ ។

## មាត្រា ១៣

## មុខងាររបស់ក្រុមប្រឹក្សាការិយាល័យ

ក្រុមប្រឹក្សាការិយាល័យត្រូវមានមុខងារដូចខាងក្រោមនេះ ÷

ក-កំណត់ និងអនុម័តលើទម្រង់ និងខ្លឹមសារនៃប័ណ្ណពណ៌ខៀវ ។

ខ-បង្កើតថវិកាប្រចាំឆ្នាំរបស់ខ្លួន និងកំណត់វិភាគទានប្រចាំឆ្នាំ ដែលត្រូវបង់ដោយការិយាល័យជាតិនីមួយៗ ។

គ-សំរបសំរួលប្រតិបត្តិការរបស់ការិយាល័យជាតិទាំងអស់ ។ ដើម្បីគោលបំណងនេះ ក្រុមប្រឹក្សាការិយាល័យត្រូវរៀបចំកិច្ចព្រមព្រៀង អន្តរការិយាល័យដែលនឹងត្រូវបានចុះហត្ថលេខា ដោយការិយាល័យជាតិទាំងអស់ និងដែលមានតែក្រុមប្រឹក្សាការិយាល័យប៉ុណ្ណោះដែលអាចធ្វើវិសោធនកម្មបាន ។

ឃ-ផ្តល់អនុសាសន៍ដល់អាជ្ញាធរពាក់ព័ន្ធ ក្នុងគោលបំណងកែលំអគំរោងការណ៍អាស៊ានស្តីពីកាតព្វកិច្ចធានារ៉ាប់រងយានយន្ត និងពង្រឹងវិធានការទប់ស្កាត់គ្រោះថ្នាក់ចរាចរផ្លូវគោក បើចាំបាច់តាមរយៈការធ្វើវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ ដែលស្ថិតនៅជាចរមានរបស់ភាគីនៃកិច្ចសន្យាទាំងឡាយ។

ង-ដោះស្រាយវិវាទរវាងការិយាល័យជាតិពីរ ឬច្រើនដែលទាក់ទងនឹងការអនុវត្តន៍ ឬការបកស្រាយបទប្បញ្ញត្តិនៃពិធីសារនេះ ។

ច- ជូនរបាយការណ៍រៀងរាល់ឆ្នាំទៅកិច្ចប្រជុំនៃនិយតករធានារ៉ាប់រងរបស់អាស៊ាន ។

ធ្វើនៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី នៅថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០០១ ជាភាសាអង់គ្លេសតែមួយច្បាប់ ។

រដ្ឋាភិបាលនៃប្រទេសប្រ៊ុយណេដារ៉ូសាឡាំ
រដ្ឋមន្ត្រីតំណាងក្រសួងហិរញ្ញវត្ថុ
PEHIN DATO HAJI ABDUL AZIZ UMAR

រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
គាត ឈន់

រដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌូណេស៊ី
រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ
PRIJADI PRAPTOSUHADJO

រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ
អនុរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ
LIANE THYKEO

រដ្ឋាភិបាលនៃប្រទេសម៉ាឡេស៊ី
រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ
TUN DAIM ZAINUDDIN

រដ្ឋាភិបាលនៃសហភាពមីយ៉ាន់ម៉ា
រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ និងចំណូល
U KHIN MAUNG THEIN

រដ្ឋាភិបាលនៃសាធារណរដ្ឋហ្វីលីពីន
រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ
ALBERTO G. ROMULO

រដ្ឋាភិបាលនៃសាធារណរដ្ឋសិង្ហបុរី
រដ្ឋមន្ត្រីទី២ក្រសួងហិរញ្ញវត្ថុ
LIM HNG KIANG

រដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡង់ដ៍

រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ
SOMKID JATUSRIPITAK

រដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម

អនុរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ
LE THI BANG TAM